# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា
# ការិយាល័យអគ្គនាយកក្រសួងអប់រំ

NORTH BROAD STREET 440
4015-19130 PENNSYLVANIA ,PHILADELPHIA

**WILLIAM R. HITE, JR., Ed.D.**
*អគ្គនាយក*


ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦

ជូនចំពោះ មាតាបិតា និង អាណាព្យាបាលៈ

យើងខ្ញុំបានដឹងថា សហជីពកម្មករផ្នែកយានជំនិះ សិពតា (SEPTA) នៃតំបន់លេខ ២៣៤ បានបោះឆ្នោតអនុញ្ញាតឲ្យសិពតាធ្វើកូដកម្ម ដែលនឹងប្រព្រឹត្តទៅនៅ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ បើសិនជាកិច្ចព្រមព្រៀងថ្មី មិនអាចចរចាគ្នាត្រូវ នៅម៉ោង ១១:៥៩ យប់ នៃថ្ងៃច័ន្ទ ទី៣១ ខែតុលា ឆ្នាំ២០១៦។ ក្នុងខណៈដែល ក្រុមហ៊ុន សិពតា សង្ឃឹមថានឹងមានការព្រមព្រៀងគ្នាតាមពេលកំណត់ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា សន្យាផ្តល់បរិយាកាសសិក្សាដែលមានសុវត្ថិភាព និងមានរបៀបរៀបរយ ដល់កូនរបស់លោកអ្នកក្នុងគ្រាដែលមានកូដកម្ម។ សូមអានព័ត៌មានខាងក្រោមនេះ និងបន្តស្តាប់វិទ្យុ KYW1060 am នៃ សេចក្តីប្រកាសរបស់ទីក្រុងហ្វីឡាដែលហ្វ្យា។ តាមដាន វិបសៃរបស់យើង [www.philasd.org](http://www.philasd.org) និង ទូរស័ព្ទមកលេខសំខាន់សម្រាប់មាតាបិតា របស់ក្រសួងអប់រំ ២១៥-៤០០-៤៦៣៦។

**ម៉ោងរៀនៈ** ក្នុងគ្រាដែលមានកូដកម្មសិពតា សាលា ការិយាល័យ និង កន្លែងជំនួយដល់ការសិក្សា ទាំងអស់ នឹងបន្តបើកតាមម៉ោងពេលធម្មតា។

**សេវាយានជំនិះ៖** រថយន្តដឹកសិស្សពណ៌លឿងទាំងអស់ នឹងប្រព្រឹត្តទៅតាមម៉ោងពេលធម្មតា ប៉ុន្តែប្រហែលជាមានការយឺតយ៉ាវខ្លះ។

**វត្តមានអវត្តមានរបស់សិស្ស៖** សិស្សានុសិស្សដែលធ្លាប់ជិះរថយន្ត សិពតា ដែលមិនអាចមករៀនបាន ដោយសារគ្មានយានជំនិះ នឹងត្រូវកត់ត្រាទុកថាជាអវត្តមានដោយមានមូលហេតុ។ ត្រូវការលិខិតបញ្ជាក់ពី មាតាបិតា ឬ អាណាព្យាបាល។ ជាបន្ថែមទៀត សិស្សានុសិស្សដែលមករៀនមិនទាន់ពេលវេលា សាលានឹងមិនកត់ត្រាទុកថាមកយឺតពេលនោះទេ លើកលែងតែនាយកសាលាសម្រេចថា ការមកយឺតពេលនោះមិនពាក់ព័ន្ធនឹងកូដកម្ម សិពតា។

យើងខ្ញុំដឹងថា លោកអ្នកប្រហែលជាមានសំណួរបន្ថែមទៀត។ យើងខ្ញុំបានផ្តល់ ចម្លើយទៅនឹងសំណួរសំខាន់ៗ នៅទំព័រម្ខាងទៀតនៃលិខិតនេះ។ យើងខ្ញុំ ស្វាគមន៍ និង សុំឲ្យមាតាបិតាទាក់ទងទៅសាលារបស់កូន ដើម្បីជ្រាបព័ត៌មានច្បាស់លាស់ អំពីសាលានោះ។

ក្នុងគ្រាដែលមានកូដកម្មយូរ ក្រសួងអប់រំនឹងផ្តល់ព័ត៌មានបន្ថែម តាមសេចក្តីត្រូវការ។

សូមអរគុណទុកជាមុនចំពោះ ការអត់ធ្មត់ និង ការយោគយល់ របស់លោកអ្នក។

ដោយសេចក្តីគោរពរាប់អាន

William R. Hite, Jr., Ed.D.

WRH/dpw

# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យា

## ចម្លើយទៅនឹងសំណួរអំពី ការធ្វើកូដកម្ម របស់ក្រុមហ៊ុន សិពតា (SEPTA)

**ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦**

១. **តើ សាលា និង ការិយាល័យរដ្ឋបាល នៅបើកឬទេ បើសិនជាក្រុមហ៊ុន សិពតា ធ្វើកូដកម្ម?**
**នៅបើក។** សាលា និង ការិយាល័យរដ្ឋបាល ទាំងអស់ នៅបើក និង រក្សាម៉ោងពេលធ្វើការតាមធម្មតា។

២. **តើកូនរបស់ខ្ញុំអាចជិះរថយន្តសាលាពណ៌លឿងទៅសាលាបានដែរឬទេ បើសិនជាក្រុមហ៊ុន សិពតា ធ្វើកូដកម្ម?**
សិស្សណាដែលបានទទួលការបម្រើឲ្យជិះរថយន្តសាលាពណ៌លឿង នៅតែបន្តទទួលការបម្រើនេះតាមធម្មតា ប៉ុន្តែមាតាបិតាត្រូវដឹងថា ប្រហែលជាអាចមានការយឺតយ៉ាវ។ គួរឲ្យស្តាយ រថយន្តសាលាពណ៌លឿងមិនអាចជូនសិស្សដែលតាមធម្មតាជិះរថយន្តសិបតាទៅសាលានោះបាន។

៣. **បើសិនជាកូនខ្ញុំមិនទៅរៀន តើសាលានឹងចាត់ទុកថាកូនខ្ញុំអវត្តមានខុសច្បាប់ ដែរឬទេ?**
**ប្រាកដណាស់។** សិស្សានុសិស្សដែលតាមធម្មតាជិះរថយន្តសិពតា ហើយមិនអាចទៅសាលា ដោយសារគ្មានយានជំនិះ នឹងត្រូវកត់ទុកថាអវត្តមាន ទៅតាមច្បាប់របស់សាលារដ្ឋ ផិនស៊ីលវេនញា។ កំណត់សម្គាល់៖ អវត្តមានដោយមានមូលហេតុ ត្រូវការលិខិតបញ្ជាក់ពីមាតាបិតា ឬ អាណាព្យាបាល។

៤. **បើសិនជាកូនរបស់ខ្ញុំទៅសាលាយឺតពេលដោយមូលហេតុនៃការធ្វើកូដកម្មរបស់ក្រុមហ៊ុនសិពតា តើសាលាចាត់ទុកថាកូនរបស់ខ្ញុំមករៀនយឺតពេលដែរឬទេ?**
សិស្សានុសិស្សដែលតាមធម្មតាជិះរថយន្តសិពតា ហើយមកដល់សាលាយឺតពេល សាលាមិនត្រូវចាត់ទុកថាមករៀនយឺតពេលទេ លើកលែងតែនាយកសាលា កត់សម្គាល់ថាការមករៀនយឺតពេលនេះមិនជាប់ពាក់ព័ន្ធនឹងការធ្វើកូដកម្មរបស់ក្រុមហ៊ុនសិពតា។

៥. **តើកូនរបស់ខ្ញុំនឹងនៅតែបន្តទទួល អាហារពេលព្រឹក និង អាហារថ្ងៃត្រង់ ដែរឬទេ?**
**នៅតែទទួល។** កម្មវិធីបម្រើម្ហូបអាហាររបស់ក្រសួងអប់រំនៅតែបន្តតាមពេលកំណត់។

៦. **តើកម្មវិធីក្រោយម៉ោងសិក្សា ដូចជាកម្មវិធី Comprehensive Early Learning Centers, extra-curricular clubs, និង កីឡា នៅតែដំណើរការនៅពេលដែលក្រុមហ៊ុនសិពតាធ្វើកូដកម្ម ដែរឬទេ?**
**នៅតែដំណើរការ។** កម្មវិធីរបស់ក្រសួងអប់រំ នៅពេលល្ងាច និង នៅថ្ងៃសៅរ៍ នៅតែដំណើរការជាធម្មតា តាមពេលកំណត់។

មាតាបិតា ដែលជិះរថយន្តសិពតាទៅទទួលកូនពីកម្មវិធីក្រោយម៉ោងសិក្សា ដូចជាកម្មវិធី Comprehensive Early Learning Centers, Beacons, និងកម្មវិធីផ្សេងៗទៀត ត្រូវធ្វើការរៀបចំផ្សេងទៀត ដើម្បីទៅយកកូនឲ្យទាន់ពេល ទោះជាក្នុងគ្រាមានកូដកម្មសិពតាក៏ដោយ។

៧. **ក្នុងគ្រាដែលមានកូដកម្មសិពតា តើក្រុមកីឡាក្រោយម៉ោងសិក្សានៅតែបន្ត ដែរឬទេ?**
**នៅតែបន្ត។ ក្រុមកីឡាក្រោយម៉ោងសិក្សា** នៅអនុវិទ្យាល័យ និង វិទ្យាល័យ នៅតែបន្តតាមពេលកំណត់។ ទោះជាដូច្នេះក៏ដោយ មាតាបិតាត្រូវធ្វើការរៀបចំផ្សេងទៀត សម្រាប់ការដឹកសិស្សមកផ្ទះ ក្រោយពេលប្រកួត ឬ ក្រោយពេលហាត់ បើសិនជាពួកគេជិះរថយន្តសិពតា។ មាតាបិតា ជាពិសេសមាតាបិតាដែលជាអ្នកជិះរថយន្តសិពតា ត្រូវធ្វើការរៀបចំដើម្បីទៅទទួលកូនពីកម្មវិធីក្រោយម៉ោងសិក្សាឲ្យទាន់ពេលវេលា។

៨. **ក្នុងពេលដែលមានកូដកម្មសិពតា តើកូនខ្ញុំអាចជិះកង់របស់ពួកគេទៅរៀនបានដែរឬទេ?**
**អាច។** នាយកសាលានឹងផ្តល់កន្លែងទុកកង់ ដែលមានសុវត្ថិភាព ដល់សិស្សានុសិស្សដែលជិះកង់មករៀន។ សិស្សានុសិស្ស និង មាតាបិតា ត្រូវចាំថា សិស្សត្រូវចាក់សោកង់ ហើយសាលាមិនទទួលខុសត្រូវដល់ការ ខូចខាត ឬ ចោរលួច កង់ទេ។

៩ **បើសិនជាកូនរបស់ខ្ញុំមិនអាចទៅរៀនបានក្នុងពេលដែលមានកូដកម្ម តើសាលាអាចផ្តល់ មេរៀន និង កិច្ចការដែលគ្រូដាក់ឲ្យធ្វើ ដល់ពួកគេដោយវិធីណា ក្នុងពេលដែលមានកូដកម្មសិពតា?**
ទោះបីជាគ្មានអ្វីអាចជំនួសការមកកាន់ថ្នាក់រៀនបាន ក្នុងពេលមានកូដកម្ម ការិយាល័យផ្នែក កម្មវិធីសិក្សា វាយតម្លៃ និង បង្ហាត់បង្រៀន នឹងផ្តល់មេរៀនសម្រាប់សិក្សា ភាសាអង់គ្លេស អក្សរសិល្ប៍ និង គណិតវិទ្យា បន្ថែម សម្រាប់សិស្សថ្នាក់មត្តេយ្យ ដល់ ថ្នាក់ទីប្រាំបី។ មេរៀន សម្រាប់សិក្សា អាចយកតាមបណ្តាញតភ្ជាប់នេះ៖ http://webgui.phila.k12.pa.us/offices/c/curriculum/learning-packets។ គ្រូនៅវិទ្យាល័យនឹងផ្តល់ឯកសារសម្រាប់រៀនទៅតាមមុខវិទ្យានីមួយៗរបស់ពួកគេ។ គ្រូទាំងអស់អាចផ្តល់ កិច្ចការដែលយកទៅធ្វើនៅផ្ទះ និង មេរៀនបន្ថែមទៀត សម្រាប់ការសិក្សាដោយខ្លួនឯង ដល់សិស្សដែលជិះសិពតា។